*សេចក្តីប្រកាសព័ត៌មាន*

***ភាពស្និតស្នាញ: ការដាក់តាំងពិព័រណ៍រូបថត***

*កាលបរិច្ឆេត៖  ចាប់ពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦ រហូតដល់ ថ្ងៃទី ៣១ ខែមករាឆ្នាំ ២០១៧*

*ទីកន្លែង: ក្លឹបអ្នកកាសែតបរទេស រាជធានីភ្នំពេញ*

*ថ្ងៃទី២៣ ខែតុលាឆ្នាំ ២០១៦ គឺជាខួបលើកទី២៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស  ដែលបានចុះហត្ថលេខាដោយភាគីជម្លោះទាំងបួនក្នុងប្រទេសកម្ពុជា និងគាំទ្រដោយ ១៨ ប្រទេស ក្នុងគោលបំណងបញ្ចប់សង្គ្រាមស៊ីវិលបែបហិង្សា។ កិច្ចព្រមព្រៀងសន្តិភាពត្រូវបានសម្គាល់ជាឱកាសយ៉ាងសំខាន់មួយសម្រាប់ប្រទេសកម្ពុជា ហើយជាខណៈពេលមួយ ដែលក្រុមផ្សេងៗគ្នាបានរួបរួមក្នុងចក្ខុវិស័យនៃសន្តិភាពសម្រាប់ប្រទេសកម្ពុជា។ បន្ទាប់ពីកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា  កិច្ចខិតខំប្រឹងប្រែងដើម្បី នាំយកប្រជាជនកម្ពុជាដែលបានភៀសខ្លួនចេញពីសង្គ្រាមត្រឡប់មកប្រទេសខ្លួនវិញ ហើយចាប់ផ្តើមកសាងប្រទេសឡើងវិញ មិនត្រឹមតែហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកសាងស្មារតីនៃជាតិកម្ពុជា។*

*ដើម្បីអបអរសាទរពីភាពស្និតស្នាញរបស់ប្រជាជនកម្ពុជាដែលគួរឱ្យកត់សម្គាល់កំឡុងពេលនោះ  វិចិត្រសាលសិល្បៈ ខនស្តេបល និងសារមន្ទីរសន្តិភាពកម្ពុជា បានសហការដាក់តាំងបង្ហាញពិព័រណ៍រូបថត បន្ទិចពីវិធីសាស្ត្រជាច្រើននៃការកសាងប្រទេសឡើងវិញឱ្យបានចេញជារូបរាង។ ពិព័រណ៍រូបថត នឹងបង្ហាញពីស្នាដៃអ្នកថតរូបបីនាក់ដែលបានចងក្រងពីទិដ្ឋភាពផ្សេងគ្នានៃការធ្វើដំណើររបស់ប្រទេសកម្ពុជា គឺ លោក ជីម ផេក  លោកហ្វូច និហ្គេល និង  លោក ចនរ៉ូស្តិដ។*

ដាក់បញ្ចូលគ្នានូវបណ្តុំនៃរូបថតបំបែកជាផ្នែកៗតាមបច្ចេកទេសនៃដំណើរសន្តិភាពមួយ ដើម្បីបង្ហាញពីដំណើររឿងរបស់ប្រជាជននៃប្រទេសមួយដែលវិលត្រឡប់មករួបរួមគ្នា បន្ទាប់ពីជម្លោះជាច្រើនទសវត្សរ៍ៗ

**លោក ជីម ផេក**



**លោក ហ្វូច និហ្គេល**



ការតាំងពិព័រណ៍ស្តីពីភាពស្និតស្នាញនេះ គឺកំពុងត្រូវបានដាក់តាំងបង្ហាញតាំងពី ថ្ងៃទី១ ខែតុលា រហូតដល់ថ្ងៃទី ៣០ ខែវិច្ឆិកា នៅវិចិត្រសាលសិល្បៈ ខនស្តេបល (Constable gallery ) និង លីថលរេដហ្វស (Little Red Fox ) ក្នុងខេត្តសៀមរាបៗ កម្មវិធីបើកព្រឹត្តិការណ៍ពិសេសស្តីពីការរំលឹកខួបនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ តុលា ធ្វើការធ្វុះបញ្ចាំងតាមរយៈ លោកស្រី Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅកម្ពុជា លោក សុត ផ្លាយង៉ាម ចក្ខុវិស័យដើម្បីសារមន្ទីរសន្តិភាពកម្ពុជា លោក ជន ចាន់ណារេត អគ្គរដ្ឋទូតនៃយុទ្ធនាការដើម្បីបញ្ឈប់ការប្រើប្រាស់គ្រាប់មីន និងលោក ជីម ផេក ជាអ្នកថតរូបៗ

ការតាំងពិព័រណ៍នេះនឹងផ្លាស់ទីតាំងទៅបង្ហាញនៅឯក្លឹបអ្នកកាសែតបរទេសនៅរាជធានីភ្នំពេញនៅ ផ្លូវ៣៦៣ ស៊ីសុវត្ថិ ក្នុងខែធ្នូនេះៗ ការបើកកម្មវិធី តាំងពិព័រណ៍នេះនឹងចាប់ផ្តើមនៅថ្ងៃទី ១៤ ខែធ្នូចាប់ពីម៉ោង៦ល្ងាច រហូតដល់ម៉ោង ៨យប់ ដោយមានការថ្លែងសន្ទរកថាបើកដោយ លោកស្រី Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅកម្ពុជា និងលោកសុត ផ្លាយង៉ាម ចក្ខុវិស័យនៃសារមន្ទីរសន្តិភាពកម្ពុជាៗ

គម្រោងសារមន្ទីរសន្តិភាពកម្ពុជាកំពុងត្រូវបានអភិវឌ្ឍឲ្យក្លាយជាកន្លែងសម្រាប់សិក្សារៀនសូត្រ ការចែករំលែកនិងការឆ្លុះបញ្ចាំងពី ការធ្វើដំណើររបស់កម្ពុជាពីជម្លោះមកកាន់សន្តិភាពដោយសង្កត់ធ្ងន់ទៅលើកិច្ចខិតខំប្រឹងប្រែងបង្កើតសន្តិភាពទាំងឡាយដែលគាំទ្រឲ្យមានការផ្លាស់ប្តូរនេះ។ការតាំងពិព័រណ៍បែបចូលរួមនឹងផ្តោតលើ ប្រធានបទដូចជាយុទ្ធនាការកម្ពុជាដើម្បីបញ្ឈប់ការប្រើប្រាស់គ្រាប់មីន ក្រុមការងារកាត់បន្ថយអាវុធនិងធម្មយាត្រាដើម្បីសន្តិភាព។

ដើម្បីស្វែងយល់បន្ថែមអំពីសារមន្ទីរសន្តិភាពកម្ពុជាសូមចូលគេហទំព័រ៖

[http://www.centrepeaceconflictstudies.org/peace-museum](http://www.centrepeaceconflictstudies.org/peace-museum)

[www.facebook.com/cambodiapeacemuseum](www.facebook.com/cambodiapeacemuseum).